ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៥.សសរ

# សេចក្តីសំរេច
# ស្តីពី
# ការបង្កើតគណៈកម្មការ
# ដើម្បីធ្វើផែនការសកម្មភាពសមាហរណកម្មអាស៊ាន

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងស្មារតីកិច្ចប្រជុំអន្តរក្រសួងនាថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០១ ស្តីពីការរៀបចំសិក្ខាសាលា ដើម្បីធ្វើផែនការការងារសំរាប់កាត់បន្ថយគំលាតអភិវឌ្ឍន៍នៅក្នុងអាស៊ាន និង ជួយបណ្តាប្រទេសសមាជិកអាស៊ានថ្មី នាថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០១

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០១

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការដើម្បីធ្វើផែនការសកម្មភាពសមាហរណកម្មអាស៊ាន ដែលមានសមាសភាពដូចតទៅ :

១- ឯកឧត្តម អ៊ុជ គឹមអ៊ន រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធាន

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ២-ឯកឧត្តម | ខែក ភារី | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៣-ឯកឧត្តម | អ៊ឹម សិទ្ធី | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៤-ឯកឧត្តម | ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៥-ឯកឧត្តម | ង៉ោ ពិន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦-ឯកឧត្តម | អ៊ូ ឪហាត | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៧-ឯកឧត្តម | ញ៉េប ប៊ុនជិន | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៨-ឯកឧត្តម | ខ្លួត រ៉ាន់ឌី | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩-ឯកឧត្តម | ឡា ណារ៉ាត | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១០-ឯកឧត្តម | កួយ គឹមសាំ | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១១-ឯកឧត្តម | ប៉ាន់ សូរស័ក្ដ | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២-ឯកឧត្តម | ឈៀង យ៉ាណារ៉ា | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានបេសកកម្ម :

-សិក្សាស្រាវជ្រាវ និងពិចារណាធ្វើផែនការសកម្មភាពសមាហរណកម្មអាស៊ាន រយៈពេលខ្លី មធ្យម និងវែង សំរាប់រយៈពេល ៦ឆ្នាំ លើវិស័យបណ្ដុះបណ្ដាលធនធានមនុស្ស ហេដ្ឋារចនា សម្ព័ន្ធ និងបច្ចេកវិទ្យាពត៌មាន ។

**ប្រការ ៣ :** ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការនេះមានភារៈកិច្ច និងសិទ្ធិ :

-សហការជាមួយបណ្ដាក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំការងារសកម្មភាព សមាហរណកម្មអាស៊ាន ។

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាលដើម្បីសុំមតិណែនាំ និងគោលការណ៍ សំរេច ។

**ប្រការ ៤ :** សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន ។ ក្នុងករណីសមាជិកណាម្នាក់មិនបានអញ្ជើញចូលរួមប្រជុំដោយជាប់រវល់ភារៈកិច្ច ត្រូវចាត់តំណាងដែលមានសិទ្ធិសំរេចអោយចូលរួមជំនួស ។

**ប្រការ ៥ :** គណៈកម្មការនេះមានលេខាធិការដ្ឋានដែលមានទីតាំងនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមានសិទ្ធិប្រើប្រាស់ត្រាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងករណីចាំបាច់ហើយ និងមានសិទ្ធិអញ្ជើញអ្នកជំនាញឯកទេសមកពីបណ្ដាក្រសួងស្ថាប័នដែលពាក់ព័ន្ធអោយចូលរួមប្រជុំ ឬជួយបំពេញការងារ ក្នុងឋានៈជាជំនួយការខាងផ្នែកបច្ចេកទេស ។

www.pheakdeylaw.com

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com